## ខ្លឹមសារសង្ខេបសាលក្រមលេខ០៩ ខែមករា ឆ្នាំ២០១១

**ពាក្យគន្លឹះ៖** ការអនុវត្តច្បាប់ថ្មី, បទបង្ករបួសដោយចេតនានិងជេរប្រមាថ, ព្យួរទោសធម្មតា

**អង្គហេតុនិងសេចក្តីសម្រេច៖** អ្នកលក់ដូរក្បែរគ្នាក្នុងផ្សារ បានអះអាងចោទទៅវិញទៅមក ថាបានវាយគ្នានិងជេរប្រមាថ ចន្លោះថ្ងៃទី១៨, ១៩និង២០ ខែសីហា ឆ្នាំ២០០៩ ពាក់ព័ន្ធនឹងការកកិតរថយន្ត។ ម្ចាស់ឡានស្នើសុំ១០ ដុល្លារ ដើម្បីជួសជុល តែភាគីម្ខាង (ស.រ.ណ) មិនព្រម។ ទោះបីជាយ៉ាងនេះក្តី មានតែមានតែជនជាប់ចោទម្នាក់ (ស.រ.ណ) ត្រូវបានគេប្តឹងពីបទបង្ករបួសដោយចេតនានិងបទជេរប្រមាថ។ ជនរងគ្រោះ (ស.ផ) បានទាមទារសំណងប្រហែលជា២០០០ដុល្លារអាមេរិក។ មានសាក្សីចំនួន៥រូបដែលជាអ្នកលក់ដូរក្បែរនោះ បានឃើញការប្រតាយគ្នានិងលឺជេរគ្នា។ក៏ប៉ុន្តែ ម្តងអះអាងថា ភាគី ស.រ.ណ បង្ក ម្តងថាភាគីម្ខាង (ស.ផ) បានបង្កហេតុ។ នេះបង្ហាញអំពីភាពមិនស៊ីសង្វាក់ ដែលមេធាវីការពារជនជាប់ចោទ បានលើកចំពោះមុខតុលាការ។ តំណាងអយ្យការ បានស្នើតម្កល់ការចោទប្រកាន់ទៅលើជនជាប់ចោទ។ ស.រ.ណ មិនធ្លាប់មានទោសពីមុនទេ។

ចៅក្រមយល់ឃើញថា ភស្តុតាងជាឯកសារនិងចម្លើយសារភាព មានភាពស៊ីសង្វាក់គ្នា បង្ហាញថាជនជាប់ចោទបានប្រព្រឹត្តដូចការចោទប្រកាន់។ ជនជាប់ចោទ គ្មានភស្តុតាងផ្លូវច្បាប់យកមកដោះសារថាខ្លួនមិនបានប្រព្រឹត្ត។ ដូចនេះ មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ។ ជនជាប់ចោទ មានស្មារតីគ្រប់គ្រាន់ដឹងខុសត្រូវ។

ក្នុងអំឡុងពេលពិចារណានោះ មាត្រា៦៣ (បទជេរប្រមាថ) នៃច្បាប់ព្រហ្មទណ្ឌ UNTAC ត្រូវបានកែសម្រួល លែងដាក់ទោសព្រហ្មទណ្ឌ ក៏ប៉ុន្តែដាក់ទោសពិន័យវិញ។ ចៅក្រម បានសម្រេចដាក់ពន្ធនាគារ៦ខែ ក៏ប៉ុន្តែទោសនេះ ត្រូវបានព្យួរធម្មតា (បទបង្ករបួស) និងពិន័យចំនួន២៥០ដុល្លា (ជេរប្រមាថ) ព្រមទាំងតម្រូវឲ្យសងជំងឺចិត្តនិងថ្លៃព្យាបាលចំនួន១ពាន់ដុល្លា ដល់ជនរងគ្រោះ។

**កំណត់សម្គាល់៖** ១. ចៅក្រម បានតម្រូវឲ្យជនជាប់ចោទបង្ហាញភស្តុតាងតាមផ្លូវច្បាប់ ដើម្បីដោះសារថា ជនជាប់ចោទមិនបានប្រព្រឹត្ត។ ប្រសិនបើការវាយតប់ជាធាតុផ្សំនៃបទល្មើស (បង្ករបួសដោយចេតនា) ការតម្រូវឲ្យបង្ហាញថា មិនបានវាយនោះ មិនមែនជាត្រឹមត្រូវទេ។ វាអាចបំពានបន្ទុកភស្តុតាងក៏ដូចជាគោលការណ៍សន្និតិមិនមានទោស។ ជនជាប់ចោទ មិនតម្រូវឲ្យបង្ហាញជាតុផ្សំនៃបទល្មើសទេ តែអាចបង្ហាញថា គាត់មិនបានប្រព្រឹត្ត ដោយសារគាត់មិននៅកន្លែងកើតហេតុ (ជាការដោះសារ)។ ២. គិតចាប់ពីថ្ងៃកើតហេតុ ខែសីហាឆ្នាំ២០០៩ ដល់ថ្ងៃសវនាការ (មករាឆ្នាំ២០១១) មានរយៈពេលមួយឆ្នាំប្រាំខែ។ ៣. មានសំណុំរឿងជេរប្រមាថស្រដៀងគ្នានេះ ដែលជនជាប់ចោទទទួលទោស៦ខែនិងទោសព្យួរដូចគ្នា។

**Summary of Judgment No. 09 (January 2011)**

**Keywords**: Application of new law, intentional violence and insult, suspended sentence.

**Facts and Court Decision**: the case involved vendors with neighboring stalls in a market who accused each other of fighting and mutual insults between August 18 and 20, 2009, following a dispute over a car scratch. The car owner requested $10 for repairs, but the other party (S.R.N.) refused. Only defendant (S.R.N.) was sued for intentional violence and insult. The victim (S.P.) demanded approximately $2,000 in compensation. Five witnesses, who were nearby vendors, saw the scuffle and heard the insults. However, their testimonies were inconsistent, sometimes claiming S.R.N. started it and other times claiming the other party (S.P.) provoked the incident. The defense lawyer highlighted these inconsistencies to the court. The prosecutor requested that the charges against the defendant be upheld. S.R.N. had no prior criminal record.

The judge found that the documentary evidence and confessions were consistent, proving the defendant committed the acts as charged. The judge noted the defendant lacked legal evidence to prove they did not commit the crime.

The court found sufficient evidence of guilt and determined the defendant was of sound mind and fully responsible for their actions. During deliberations, Article 63 (Insult) of the UNTAC Criminal Law was amended to replace criminal imprisonment with a fine.

The judge sentenced the defendant to 6 months in prison, but the sentence was fully suspended (for the charge of intentional violence). Additionally, the defendant was fined $250 (for the insult) and ordered to pay $1,000 in compensation and medical expenses to the victim.

**Observations and Notes**: **1**. The judge required the defendant to provide legal evidence to prove they did not commit the act. If physical violence is an essential element of the crime (intentional violence), requiring the defendant to prove they did not strike the other party may be incorrect. This could violate the burden of proof and the principle of the presumption of innocence. While a defendant is not required to disprove the elements of a crime, they may provide evidence such as an *alibi* (being elsewhere) as a defense. **2.** there was a period of one year and five months between the incident (August 2009) and the trial (January 2011) and **3**. there are similar cases regarding insults where defendants also received a 6-month suspended sentence.